# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ...៤៧...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការរៀបចំ និង ការប្រព្រឹត្តទៅ
## នៃវិទ្យាស្ថានស្តង់ដារកម្ពុជា

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នា២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នា១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នា១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នា២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នា១៩៩៨ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នា២០០២ ស្តីពីការតម្លើងការិយាល័យអាស៊ាន និងការិយាល័យស្តង់ដារឧស្សាហកម្ម ទៅជានាយកដ្ឋានសហប្រតិបត្តិការនិងការងារអាស៊ាន និងជា នាយកដ្ឋានស្តង់ដារឧស្សាហកម្មកម្ពុជានៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

# ស ម្រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះកំណត់អំពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃវិទ្យាស្ថានស្តង់ដារកម្ពុជា នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

## ជំពូកទី ២
## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា ២ .-**

មុខងារនិងភារកិច្ចសំខាន់ៗ របស់វិទ្យាស្ថានស្តង់ដារកម្ពុជាមានជាអាទិ៍ ដូចខាងក្រោម :

- រៀបចំស្តង់ដារជាតិសម្រាប់ផលិតផល ទំនិញ សម្ភារៈ សេវា ការអនុវត្ត និងការប្រតិបត្តិ និងផ្សព្វផ្សាយ ដើម្បីឱ្យមានការទទួលយកជាទូទៅនៃស្តង់ដារទាំងនោះ
- អនុវត្តការវាយតម្លៃភាពអនុលោមស្របតាមបញ្ញត្តិ ដែលមានចែងក្នុងច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បង្កើតនិងថែទាំមន្ទីរពិសោធន៍ បណ្ណាល័យ មធ្យោបាយនិងឧបករណ៍ផ្សេងទៀត ដើម្បីលើកកម្ពស់ស្តង់ដារូបនីយកម្មនិងគុណភាព
- បញ្ជាក់ភាពអនុលោមតាមស្តង់ដារសម្រាប់ផលិតផល ទំនិញ សារធាតុ សម្ភារៈ និងបរិក្ខារសម្រាប់ការប្រើប្រាស់ក្នុងស្រុក ឬសម្រាប់ការនាំចេញតាមសំណើរបស់អ្នកស្នើសុំ
- បញ្ជាក់ភាពអនុលោមតាមស្តង់ដារសុវត្ថិភាព សម្រាប់ផលិតផល ទំនិញ សារធាតុ សម្ភារៈ និងបរិក្ខារសម្រាប់ការប្រើប្រាស់ក្នុងស្រុក ឬសម្រាប់ការនាំចេញតាមសំណើរបស់អ្នកស្នើសុំ
- បញ្ជាក់ភាពអនុលោមតាមស្តង់ដារសម្រាប់ប្រព័ន្ធគ្រប់គ្រងផលិតកម្មនិងសេវាកម្ម តាមសំណើរបស់អ្នកស្នើសុំ
- ព្យួរទុក ដកហូត និងលុបចោលអាជ្ញាប័ណ្ណបញ្ជាក់ផលិតផល ឬវិញ្ញាបនបត្របញ្ជាក់ភាពអនុលោម ឬវិញ្ញាបនបត្របញ្ជាក់ឬចុះបញ្ជីប្រព័ន្ធ ឬវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ឬចុះបញ្ជី
- ស្រាវជ្រាវអំពីស្តង់ដារូបនីយកម្ម
- ផ្តល់សេវាអប់រំ បណ្តុះបណ្តាល និងការពិគ្រោះយោបល់ ដើម្បីផ្សព្វផ្សាយស្តង់ដារូបនីយកម្ម និងគុណភាព
- ទទួលស្គាល់មន្ទីរពិសោធន៍ មធ្យោបាយ និងឧបករណ៍ផ្សេងទៀតរបស់អង្គភាពក្នុងស្រុក និងបរទេសសម្រាប់គោលបំណងរបស់វិទ្យាស្ថាន

- ផ្តល់កិច្ចសហប្រតិបត្តិការជាមួយបុគ្គល អង្គការអន្តរជាតិ ឬសមាគមក្រៅប្រទេស ដែលមានកម្មវត្ថុនិងគោលបំណងដូចគ្នា
- ជំរុញនិងលើកទឹកចិត្តការអនុវត្តស្តង់ដារ និងស្តង់ដារូបនីយកម្មឱ្យទៅជាមធ្យោបាយមួយសម្រាប់ការរីកចម្រើននៃសេដ្ឋកិច្ចជាតិ សម្រាប់សុខភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ
- សហការជាមួយអាជ្ញាធរមូលដ្ឋាន វិស័យឧស្សាហកម្ម ពាណិជ្ជកម្ម និងអង្គការនានា ដើម្បីធានានូវការអនុវត្តស្តង់ដារ ។

**មាត្រា ៣ .-**

វិទ្យាស្ថានស្តង់ដារកម្ពុជា ដឹកនាំដោយប្រធានមួយរូបមានឋានៈស្មើអគ្គនាយក និងមានអនុប្រធានមួយរូប ឬ ច្រើនរូបតាមការចាំបាច់ ។

**មាត្រា ៤ .-**

វិទ្យាស្ថានស្តង់ដារកម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ ÷

- នាយកដ្ឋានព័ត៌មាន
- នាយកដ្ឋានអភិវឌ្ឍស្តង់ដារ បណ្តុះបណ្តាល និងពិគ្រោះយោបល់
- នាយកដ្ឋានវិញ្ញាបនបត្រកម្ម
- នាយកដ្ឋានបញ្ញត្តកម្ម និងវាយតម្លៃទទួលស្គាល់ ។

អង្គការលេខរបស់វិទ្យាស្ថានស្តង់ដារកម្ពុជា ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ៥ .-**

នាយកដ្ឋានព័ត៌មាន មានតួនាទីនិងភារកិច្ចដូចតទៅ ÷

- គ្រប់គ្រង និងបែងចែកលិខិតចេញ-ចូលរបស់វិទ្យាស្ថាន
- រៀបចំពិធីការក្នុងការទទួលភ្ញៀវ សិក្ខាសាលា វគ្គបណ្តុះបណ្តាល កិច្ចប្រជុំ និងពិធីផ្សេងៗដែលពាក់ព័ន្ធនឹងការងាររបស់វិទ្យាស្ថាន
- ធ្វើការងារគ្រប់គ្រងមន្ត្រីរាជការក្នុងវិទ្យាស្ថាន
- រៀបចំគម្រោងថវិកា និងសហការជាមួយនាយកដ្ឋានជំនាញ ដើម្បីលើកគម្រោងសុំថវិកា និងសម្ភារៈបរិក្ខារសម្រាប់បំរើការនៅក្នុងវិទ្យាស្ថាន
- ទទួលបន្ទុកការងារបង់កម្រៃអាជ្ញាប័ណ្ណជូនរដ្ឋ
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ និងធ្វើបញ្ជីសារពើភ័ណ្ឌរបស់វិទ្យាស្ថាន

- រៀបចំបែបបទ និងនីតិវិធីផ្តល់និងទទួលព័ត៌មានទាក់ទងទៅនឹងច្បាប់ បទប្បញ្ញត្តិបច្ចេកទេស ស្តង់ដារូបនីយកម្ម ការវាយតម្លៃភាពអនុលោម និងការធានាគុណភាព ក្នុងនិងក្រៅប្រទេស
- ទទួលបន្ទុកជាចំណុចកណ្តាលក្នុងការឆ្លើយតបទៅនឹងសំនួរ-ចម្ងល់របស់អតិថិជន ឬភាគីពាក់ព័ន្ធ ទាំងក្នុងនិងក្រៅប្រទេស អំពីព័ត៌មានទាក់ទងនឹងរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម
- រៀបចំបោះពុម្ពនិងផ្សព្វផ្សាយឯកសារស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស ព្រឹត្តិប័ត្រ និងលិខិតផ្សេងៗ របស់វិទ្យាស្ថាន
- គ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគ្រប់គ្រងបណ្ណាល័យរបស់វិទ្យាស្ថាន
- បូកសរុបនិងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់វិទ្យាស្ថាន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានវិទ្យាស្ថានប្រគល់ជូន។

**មាត្រា ៦ .-**

នាយកដ្ឋានអភិវឌ្ឍស្តង់ដារ បណ្តុះបណ្តាល និងពិគ្រោះយោបល់មានតួនាទីនិងភារកិច្ចដូចតទៅ ÷

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍស្តង់ដារជាតិ
- សិក្សាស្រាវជ្រាវនិងរៀបចំឯកសារស្តង់ដារជាតិ រៀបចំគោលការណ៍លើកទឹកចិត្តអតិថិជនឱ្យប្រើប្រាស់ស្តង់ដារកម្ពុជា តាមរយៈការជំរុញឱ្យបង្កើតសមាគមផលិតករ និងសមាគមអ្នកប្រើប្រាស់ និងគោលការណ៍ណែនាំនានា
- ធ្វើជាជំនួយការឱ្យរាល់គណៈកម្មការបច្ចេកទេសស្តង់ដារក្នុងការកំណត់ស្តង់ដារនិមួយៗ
- ចូលរួមជាមួយសមាគមក្រៅប្រទេស អង្គការពាណិជ្ជកម្មពិភពលោក និងអង្គការអន្តរជាតិនានា ក្នុងការរៀបចំស្តង់ដារ និងកិច្ចព្រមព្រៀងទទួលស្គាល់ទៅវិញទៅមក ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ
- ផ្តល់ការណែនាំអំពីការប្រើប្រាស់ និងការអនុវត្តស្តង់ដារជាតិ ដល់ក្រុមហ៊ុន រោងចក្រ សហគ្រាស និង អង្គភាពពាក់ព័ន្ធនានា
- សហការជាមួយក្រុមហ៊ុន រោងចក្រ សហគ្រាស និងអង្គភាពពាក់ព័ន្ធ ដើម្បីជំរុញសកម្មភាពស្តង់ដារូបនីយកម្មឱ្យបានត្រឹមត្រូវ
- ធ្វើអត្តសញ្ញាណកម្ម និងរៀបចំផែនការសម្រាប់ធ្វើការបណ្តុះបណ្តាលអំពីស្តង់ដារូបនីយកម្ម
- ប្រតិបត្តិ និងគ្រប់គ្រងសកម្មភាពបណ្តុះបណ្តាល ដោយសហការជាមួយនាយកដ្ឋាននានា ចំណុះវិទ្យាស្ថាន
- សហប្រតិបត្តិការជាមួយអ្នកជំនាញការជាតិនិងអន្តរជាតិ ក្នុងការបណ្តុះបណ្តាល និងការពិគ្រោះយោបល់អំពីស្តង់ដារូបនីយកម្ម ការវាយតម្លៃភាពអនុលោម និងការធានាគុណភាព

- ផ្តល់សេវាពិគ្រោះយោបល់តាមការស្នើសុំរបស់ក្រុមហ៊ុន រោងចក្រ សហគ្រាស និងអង្គភាពនានា ដែលរៀបចំស្នើសុំវិញ្ញាបនបត្របញ្ជាក់ភាពអនុលោមតាមស្តង់ដារសម្រាប់ផលិតផល និង វិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធគ្រប់គ្រង
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានវិទ្យាស្ថានប្រគល់ជូន។

**មាត្រា ៧ .-**

នាយកដ្ឋានវិញ្ញាបនបត្រកម្ម មានតួនាទីនិងភារកិច្ចដូចតទៅ ÷

- រៀបចំបែបបទ និងនីតិវិធីសម្រាប់ចេញវិញ្ញាបនបត្របញ្ជាក់ភាពអនុលោមតាមស្តង់ដារផលិតផល សុវត្ថិភាព និងប្រព័ន្ធគ្រប់គ្រងមានជាអាទិ៍ ISO 9001, ISO 14001, ISO 22000, HACCP, GMP លើកលែងតែផលិតផលឱសថ បរិក្ខារពេទ្យ និងគ្រឿងសំអាង
- រៀបចំកិច្ចព្រមព្រៀងឬកិច្ចសន្យារបស់ក្រុមហ៊ុន រោងចក្រ សហគ្រាស និងអង្គភាពនានាពាក់ព័ន្ធ នឹងការអនុវត្តតាមការតម្រូវនៃប្រព័ន្ធចេញវិញ្ញាបនបត្របញ្ជាក់ភាពអនុលោមតាមស្តង់ដារ ផលិតផលឬប្រព័ន្ធគ្រប់គ្រង
- ធ្វើអធិការកិច្ចនៅក្នុងក្រុមហ៊ុន រោងចក្រ សហគ្រាស និងអង្គភាពនានា ដែលបានស្នើសុំ និងដែល បានទទួលវិញ្ញាបនបត្របញ្ជាក់ភាពអនុលោមតាមស្តង់ដារផលិតផល
- ធ្វើសវនកម្មនៅក្នុងក្រុមហ៊ុន រោងចក្រ សហគ្រាស និងអង្គភាពនានា ដែលបានស្នើសុំ និងដែល បានទទួលវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធគ្រប់គ្រង
- ចូលរួមធ្វើសវនកម្មជាមួយអង្គភាពចេញវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធគ្រប់គ្រងនានាតាមការស្នើសុំ
- រៀបចំបែបបទ និងនីតិវិធីសម្រាប់ការពន្យារពេល ការព្យួរទុក ការដកហូត និងការលុបចោល វិញ្ញាបនបត្របញ្ជាក់ភាពអនុលោមតាមស្តង់ដារសម្រាប់ផលិតផល ឬ ប្រព័ន្ធគ្រប់គ្រងរបស់ ក្រុមហ៊ុន រោងចក្រ សហគ្រាស និងអង្គភាពនានា
- ចូលរួមជាមួយសមាគមក្រៅប្រទេស អង្គការពាណិជ្ជកម្មពិភពលោក និងអង្គការអន្តរជាតិនានា ក្នុងការវាយតម្លៃភាពអនុលោម និងរៀបចំអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់ទៅវិញទៅមក ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានវិទ្យាស្ថានប្រគល់ជូន។

**មាត្រា ៨ .-**

នាយកដ្ឋានបញ្ញត្តកម្ម និង វាយតម្លៃទទួលស្គាល់ មានតួនាទីនិងភារកិច្ចដូចតទៅ ÷

- រៀបចំបង្កើតសញ្ញាស្តង់ដារកម្ពុជា
- រៀបចំបែបបទ និង នីតិវិធី សម្រាប់ការចុះបញ្ជីផលិតផលប្រើសញ្ញាស្តង់ដារកម្ពុជា តាមការស្នើសុំ
- រៀបចំបែបបទ និង នីតិវិធី សម្រាប់ការចេញអាជ្ញាប័ណ្ណបញ្ជាក់ផលិតផល តាមការស្នើសុំ
- រៀបចំបែបបទ និង នីតិវិធី សម្រាប់ការចុះបញ្ជីនិងចេញវិញ្ញាបនបត្រចុះបញ្ជីចំពោះបុគ្គលឬអង្គភាពណាមួយ ដែលមានបំណងផ្សព្វផ្សាយពាណិជ្ជកម្មអំពីការទទួលបាននូវវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធគ្រប់គ្រងណាមួយ លើកលែងតែផលិតផលឱសថ បរិក្ខារពេទ្យ និងគ្រឿងសំអាង
- រៀបចំនិងគ្រប់គ្រងស្តង់ដារ និងបញ្ជាក់មុខសញ្ញា និង/ឬស្តង់ដារប្រើប្រាស់សារធាតុគីមីក្នុងវិស័យឧស្សាហកម្ម តាមការស្នើសុំ
- រៀបចំបែបបទ និងនីតិវិធី សម្រាប់ការចេញលិខិតបញ្ជាក់ទំនិញនាំចូល ចំពោះផលិតផលដែលត្រូវអនុលោមតាមបញ្ញត្តិបច្ចេកទេស ឬ ស្តង់ដារបញ្ជា តាមតម្រូវការរបស់សមត្ថកិច្ចពាក់ព័ន្ធ និងតាមការស្នើសុំ
- រៀបចំកិច្ចព្រមព្រៀងឬកិច្ចសន្យាពាក់ព័ន្ធនឹងការប្រើអាជ្ញាប័ណ្ណ
- ចុះធ្វើអធិការកិច្ច តាមការកំណត់ដូចមានចែងក្នុងមាត្រា៧ និងមាត្រា៨ នៃច្បាប់ស្តីពីស្តង់ដារកម្ពុជា
- រៀបចំបែបបទ និងនីតិវិធីសម្រាប់ការពន្យារពេល ការព្យួរទុក ការដកហូត និងការលុបចោលអាជ្ញាប័ណ្ណ
- ជំរុញឱ្យផលិតផលមានការប្រើសញ្ញាស្តង់ដារ និងមានការប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព ព្រមទាំងជំរុញការប្រកួតប្រជែងត្រឹមត្រូវនៅក្នុងការធ្វើពាណិជ្ជកម្ម
- រៀបចំគោលការណ៍ណែនាំ និងផ្តល់យោបល់ក្នុងការកំណត់ស្តង់ដារបញ្ជា ឬបញ្ញត្តិបច្ចេកទេស
- សិក្សា ស្រាវជ្រាវ និងផ្សព្វផ្សាយអំពីផលិតផល ទំនិញ សម្ភារៈដែលមានភាពគ្រោះថ្នាក់ដល់សុខភាព សុវត្ថិភាព បរិស្ថាន និងទ្រព្យសម្បត្តិសង្គម ដោយសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ
- ចូលរួមក្នុងការអនុវត្តកិច្ចព្រមព្រៀងពាក់ព័ន្ធជាមួយអង្គភាពបញ្ញត្តកម្មអន្តរជាតិ តំបន់ និងប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនិងអង្គការអន្តរជាតិនានា ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ
- រៀបចំបែបបទ និង នីតិវិធីសម្រាប់ចេញវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ឬវិញ្ញាបនបត្រចុះបញ្ជីអង្គភាពវាយតម្លៃភាពអនុលោម មន្ទីរពិសោធន៍ធ្វើតេស្តឬក្រិតខ្នាត អង្គភាពបណ្តុះបណ្តាលសម្រាប់ការវាយតម្លៃភាពអនុលោម និងបុគ្គលណាមួយដែលមានលក្ខណសម្បត្តិដើម្បីវាយតម្លៃភាពអនុលោម

- មិនត្រូវបានអនុញ្ញាតឱ្យធ្វើការវាយតម្លៃទទួលស្គាល់ ចំពោះអង្គភាពវាយតម្លៃភាពអនុលោម និង មន្ទីរពិសោធន៍ដែលនៅចំណុះវិទ្យាស្ថានឡើយ
- រៀបចំកិច្ចព្រមព្រៀង ឬកិច្ចសន្យារបស់អង្គភាពវាយតម្លៃភាពអនុលោម មន្ទីរពិសោធន៍ធ្វើតេស្តឬក្រិតខ្នាត អង្គភាពបណ្តុះបណ្តាលសម្រាប់ការវាយតម្លៃភាពអនុលោម និងបុគ្គលណាមួយដែលមានលក្ខណសម្បត្តិដើម្បីវាយតម្លៃភាពអនុលោមពាក់ព័ន្ធនឹងការអនុវត្តតាមការតម្រូវនៃប្រព័ន្ធចេញវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ឬវិញ្ញាបនបត្រចុះបញ្ជី
- ធ្វើសវនកម្មក្នុងអង្គភាពវាយតម្លៃភាពអនុលោម មន្ទីរពិសោធន៍ធ្វើតេស្ត ឬក្រិតខ្នាតអង្គភាពបណ្តុះបណ្តាលសម្រាប់ការវាយតម្លៃភាពអនុលោម និងបុគ្គលណាមួយដែលមានលក្ខណសម្បត្តិដើម្បីវាយតម្លៃភាពអនុលោម ដែលស្ថិតនៅក្រៅក្របខ័ណ្ឌរបស់វិទ្យាស្ថាន និងដែលបានស្នើសុំ និងដែលបានទទួលវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជី
- រៀបចំបែបបទ និងនីតិវិធីសម្រាប់ការពន្យារពេល ការព្យួរទុក ការដកហូត និងការលុបចោលវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រចុះបញ្ជី
- ចូលរួមសហការជាមួយសមាគមក្រៅប្រទេស អង្គការពាណិជ្ជកម្មពិភពលោក និងអង្គការអន្តរជាតិនានា ក្នុងការវាយតម្លៃទទួលស្គាល់និងចុះបញ្ជី និងរៀបចំអនុវត្តកិច្ចព្រមព្រៀងនានា
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានវិទ្យាស្ថានប្រគល់ជូន។

**មាត្រា ៩.-**

នាយកដ្ឋាននិមួយៗ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាននិមួយៗ នៃវិទ្យាស្ថានស្តង់ដារកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

## ជំពូកទី ៣
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

នាយកដ្ឋានស្តង់ដារឧស្សាហកម្មកម្ពុជា ដែលបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០២ និង បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០០៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធ អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០០៨**

## អង្គការលេខ នៃ វិទ្យាស្ថានស្តង់ដារកម្ពុជា

